00208247

Declassified to Public
06 September 2012

ឯកសារ/N° C3/II

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 07 / 2008
ម៉ោង (Time/Heure): 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein des Tribunaux Cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 001/18-07-2007-ECCC-OCIJ**

# ដីកាសម្រេចអំពីការបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន
# Order on extension of provisional detention
# Ordonnance sur la prolongation de la détention provisoire

យើង **យូ ប៊ុនឡេង** និង **Marcel Lemonde** (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 28 / 07 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

បានឃើញវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ភេទប្រុស កើតថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ១៩៤២

ត្រូវបានដាក់អោយស្ថិតក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសដែលមានចែង



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

00208248

ការ/N·C3/II

និងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៧ (C3/10)

បានឃើញដីកាបំបែកសំណុំរឿងចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០០៧ (D18)

បានឃើញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០០៧ (C5/45)

បានឃើញសេចក្តីជូនដំណឹងចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៨ ដែលក្នុងនោះយើងបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ខ្លួនអំពីគោលបំណងរបស់យើងក្នុងការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ដែលនឹងត្រូវផុតរលត់នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៨ ហើយនិងបានឲ្យជាដំណឹងដល់ពួកគេថា ពួកគេមានរយៈ១៥ថ្ងៃ ដើម្បីធ្វើការកត់សម្គាល់ ឬតវ៉ាមកយើង (C3/I)

បានឃើញថាមេធាវីរបស់ជនត្រូវចោទមិនមានធ្វើកំណត់សម្គាល់ ឬការតវ៉ាមកយើងក្នុងរយៈពេលកំណត់១៥ថ្ងៃ

ដោយហេតុថាដីកាដំណោះស្រាយនៃសំណុំរឿងនេះនឹងត្រូវចេញក្នុងប៉ុន្មានសប្តាហ៍ខាងមុខនេះ តែមិនមែនមុនថ្ងៃ៣១ ខែកក្កដា ឆ្នាំ២០០៨ នោះទេ

ដោយហេតុថាលក្ខខ័ណ្ឌនានាដែលមានកំណត់នៅក្នុងវិធាន ៦៣.៣ ត្រូវបានបំពេញ ដូចគ្នានិងអំណះអំណាងហេតុផលរបស់អង្គបុរេជំនុំជម្រះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧ នៅតែមានសុពលភាពដដែល



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

00208249

ឃ៣៧/៣ C3/II

អាស្រ័យហេតុនេះ

សម្រេចឱ្យមានការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងរយៈពេលអតិបរមាចំនួនមួយឆ្នាំទៀត ដោយអនុលោមតាមបទប្បញ្ញត្តិនៃវិធាន ៦៣.៦ (ក)។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-juges d'instruction**

MARCEL Lemonde

យូ ប៊ុនឡេង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.